ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៧១៩៦/២៥ មសប្រក

# ប្រកាស
## ស្ដីពី
## ការដាក់ឱ្យអនុវត្តទម្រង់នៃសេចក្ដីសម្រេចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្ដែកលើកិច្ចព្រមព្រៀងការងារ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យអនុវត្តទម្រង់នៃសេចក្ដីសម្រេចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ដូចមានខ្លឹមសារជាឧបសម្ព័ន្ធនៃប្រកាសនេះ។



ផ្លូវវត្តអង្គតាមិញ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្ពុជា
St. Watangtaminh, Sangkat Chomchoa, Khan Posenchey,
Phnom Penh, CAMBODIA
ទូរស័ព្ទ : (+៨៥៥) ២៣ ៨៦៦ ៥០១
Phone : (+855) 23 866 501
www.mcs.gov.kh

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះប្រធានអង្គភាពសាមី មន្ត្រីផ្នែកលើកិច្ចព្រមព្រៀងការងារ និងមន្ត្រីដែលពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្នែកលើកិច្ចព្រមព្រៀងការងារ ដោយអនុលោមតាមអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្តីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្នែកលើកិច្ចព្រមព្រៀងការងារ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ នាយកសាលាភូមិន្ទរដ្ឋបាល អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាននានា អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ២១៩៦/២៦ មស.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ ស្តីពីការដាក់ឱ្យអនុវត្តទម្រង់នៃសេចក្តីសម្រេចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ។

# ទម្រង់នៃសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការវិន័យ ចំពោះមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្ត.................**

**អង្គភាព.........................**

**លេខ:............................**

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការវិន័យចំពោះមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ

**ប្រធានអង្គភាព....................................**

- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៧ ស្តីពីនីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្តីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- បានឃើញប្រកាសលេខ៣៩២៣/២៥ មស.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តទម្រង់គំរូលិខិតពាក់ព័ន្ធនឹងការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមកិច្ចព្រមព្រៀងការងារ ចុះថ្ងៃទី... ខែ... ឆ្នាំ២០...
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការវិន័យនៅអង្គភាព... ដែលមានសមាសភាពចំនួន... រូប ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក/លោកស្រី... | ប្រធានអង្គភាព | ប្រធាន |
| ២. លោក/លោកស្រី... | អនុប្រធានអង្គភាព | អនុប្រធាន |
| ៣. លោក/លោកស្រី... | ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ | សមាជិក |
| ៤. លោក/លោកស្រី... | មន្ត្រីជំនាញនៃអង្គភាព | សមាជិក |
| ៥. លោក/លោកស្រី... | មន្ត្រីជំនាញនៃអង្គភាព | សមាជិក។ |

**ប្រការ២ .-**

គណៈកម្មការវិន័យមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តឱ្យបានត្រឹមត្រូវស្របតាមអនុក្រឹត្យស្តីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើការស៊ើបអង្កេត និងសិក្សាស្រាវជ្រាវឱ្យបានច្បាស់លាស់លើកំហុសឆ្គងរបស់មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ដែលត្រូវបានចោទប្រកាន់មុននឹងពិនិត្យ សម្រេច ដាក់ទណ្ឌកម្ម
- ធ្វើកំណត់ហេតុ របាយការណ៍ និងរៀបចំសំណុំរឿងតាមករណីនីមួយៗ ដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេត
- កោះប្រជុំគណៈកម្មការវិន័យ ដើម្បីសម្រេចដាក់វិន័យចំពោះមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ឬលើកសំណើជូនគណៈវិជ្ជាជីវៈតាមវិស័យ ឬជំនាញវិជ្ជាជីវៈនីមួយៗ តាមយន្តការ បែបបទ និងនីតិវិធីជាធរមាន។

**ប្រការ៣ .-**

គ្រប់អង្គភាពពាក់ព័ន្ធនៃអង្គភាព... និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...................... ខែ...................... ឆ្នាំ............ ...ស័ក ព.ស.២៥...

ធ្វើនៅ...................... ថ្ងៃទី... ខែ... ឆ្នាំ២០...

**ប្រធានអង្គភាព**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ...រាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
  «ដើម្បីជូនជ្រាប»
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការិយាល័យ...
- ដូចប្រការ៣ «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...១២១៥៦/២៦ មសៈប្រក... ចុះថ្ងៃទី...២៣...ខែ...មេសា... ឆ្នាំ២០២៦ ស្ដីពីការដាក់ឱ្យអនុវត្តទម្រង់នៃសេចក្ដីសម្រេចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ។

# ទម្រង់នៃសេចក្ដីសម្រេចស្ដីពីការអនុវត្តទណ្ឌកម្មខាងវិន័យ ចំពោះមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត**..................

**អង្គភាព**..........................

លេខៈ..............................

## សេចក្ដីសម្រេច
## ស្ដីពី
## ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ

**ប្រធានអង្គភាព**..................

- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្ដីពីរបបស្ដីពីការសុំច្បាប់និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- បានឃើញប្រកាសលេខ ៣៩២៣/២៥ មស.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ស្ដីពីការដាក់ឱ្យអនុវត្តទម្រង់គំរូលិខិតពាក់ព័ន្ធនឹងការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមកិច្ចព្រមព្រៀងការងារ ចុះថ្ងៃទី... ខែ... ឆ្នាំ២០...
- យោងតាមរបាយការណ៍វាយតម្លៃសមិទ្ធកម្មការងាររបស់អង្គភាព... ចុះថ្ងៃទី... ខែ... ឆ្នាំ២០...
- យោងតាមស្មារតីកិច្ចប្រជុំគណៈកម្មការវិន័យ ចុះថ្ងៃទី... ខែ... ឆ្នាំ...

## សម្រេច

**ប្រការ១ .-**

ត្រូវបានអនុវត្តទណ្ឌកម្មខាងវិន័យចំពោះលោក/លោកស្រី... លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ... បច្ចុប្បន្នជាមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ បម្រើការងារនៅអង្គភាព... តាមរូបភាព... (ស្តីបន្ទោស/ព្យួរកិច្ចព្រមព្រៀងការងារ/បញ្ចប់កិច្ចព្រមព្រៀងការងារ) មូលហេតុ..........................................................................។

**ប្រការ២ .-**

គ្រប់អង្គភាពពាក់ព័ន្ធនៃអង្គភាព... និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/

ថ្ងៃ...................... ខែ...................... ឆ្នាំ........... ...ស័ក ព.ស.២៥...

ធ្វើនៅ...................... ថ្ងៃទី... ខែ... ឆ្នាំ២០...

**ប្រធានអង្គភាព**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ...រាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

  «ដើម្បីជូនជ្រាប»
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការិយាល័យ...
- ដូចប្រការ២ «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ២១៥៩/២៦ មស.ប្រក... ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ ស្តីពីការដាក់ឱ្យអនុវត្តទម្រង់នៃសេចក្តីសម្រេចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ។

**ទម្រង់នៃសេចក្តីសម្រេចស្តីពីការបន្តកិច្ចព្រមព្រៀងការងារ**
**ជូនមន្ត្រីដែលបំពេញការងារសាកល្បងបានជោគជ័យ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត.................**
**អង្គភាព.........................**
**លេខ:............................**

**សេចក្តីសម្រេច**
**ស្តីពី**
**ការបន្តកិច្ចព្រមព្រៀងការងារជូនមន្ត្រីដែលបំពេញការងារសាកល្បងបានជោគជ័យ**

**ប្រធានអង្គភាព......................................**

- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្តីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- បានឃើញប្រកាសលេខ ៣៩២៣/២៥ មស.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការដាក់ឱ្យអនុវត្តទម្រង់គំរូលិខិតពាក់ព័ន្ធនឹងការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមកិច្ចព្រមព្រៀងការងារ ចុះថ្ងៃទី... ខែ... ឆ្នាំ២០...
- យោងតាមរបាយការណ៍វាយតម្លៃសមិទ្ធកម្មការងាររបស់អង្គភាព... ចុះថ្ងៃទី... ខែ... ឆ្នាំ២០...

**សម្រេច**

**ប្រការ១ .-**

ត្រូវបានអនុញ្ញាតឱ្យលោក/លោកស្រី... អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ... បន្តកិច្ចព្រមព្រៀងការងារនៅអង្គភាព... ដល់ថ្ងៃទី... ខែ... ឆ្នាំ២០... ដែលបំពេញការងារសាកល្បងរយៈពេល ៣(បី)ខែ បានជោគជ័យ។

**ប្រការ២ .-**

គ្រប់អង្គភាពពាក់ព័ន្ធនៃអង្គភាព... និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ..................... ខែ...................... ឆ្នាំ........... ...ស័ក ព.ស.២៥...

ធ្វើនៅ...................... ថ្ងៃទី... ខែ... ឆ្នាំ២០...

**ប្រធានអង្គភាព**

**កន្លែងទទួល៖**
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ...រាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
  «ដើម្បីជូនជ្រាប»
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការិយាល័យ...
- ដូចប្រការ២ «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ២១៩៦/២៦ មស.ប្រក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ ស្ដីពីការដាក់ឱ្យអនុវត្តទម្រង់នៃសេចក្ដីសម្រេចពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ។

## ទម្រង់នៃសេចក្ដីសម្រេចស្ដីពីការបញ្ចប់កិច្ចព្រមព្រៀងការងារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត**.......................
**អង្គភាព**..............................
លេខ:...................................

## សេចក្ដីសម្រេច
## ស្ដីពី
## ការបញ្ចប់កិច្ចព្រមព្រៀងការងារ

**ប្រធានអង្គភាព**..............................

- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- បានឃើញប្រកាសលេខ ៣៩២៣/២៥ មស.ប្រក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ស្ដីពីការដាក់ឱ្យអនុវត្តទម្រង់គំរូលិខិតពាក់ព័ន្ធនឹងការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ
- យោងតាមកិច្ចព្រមព្រៀងការងារ ចុះថ្ងៃទី... ខែ... ឆ្នាំ២០...
- យោងតាមរបាយការណ៍សមិទ្ធកម្មការងាររបស់មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ចុះថ្ងៃទី... ខែ... ឆ្នាំ២០...
- យោងតាមរបាយការណ៍វាយតម្លៃសមិទ្ធកម្មការងាររបស់អង្គភាព... ចុះថ្ងៃទី... ខែ... ឆ្នាំ២០... ឬ
- យោងតាមស្មារតីកិច្ចប្រជុំគណៈកម្មការវិន័យ ចុះថ្ងៃទី... ខែ... ឆ្នាំ... ឬ
- យោងតាមសំណើសុំរបស់...(សាមីខ្លួន)

## សម្រេច

**ប្រការ១ .-**

ត្រូវបានបញ្ចប់កិច្ចព្រមព្រៀងការងារលោក/លោកស្រី... លេខអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ... បច្ចុប្បន្នជា... បម្រើការងារនៅអង្គភាព... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០... មូលហេតុ...។

**ប្រការ២ .-**

ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងទៀតរបស់លោក/លោកស្រី... ត្រូវបានកាត់ផ្ដាច់ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០... តទៅ។

**ប្រការ៣ .-**

គ្រប់អង្គភាពពាក់ព័ន្ធនៃអង្គភាព... និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...................... ខែ...................... ឆ្នាំ............ ...ស័ក ព.ស.២៥...

ធ្វើនៅ...................... ថ្ងៃទី... ខែ... ឆ្នាំ២០...

**ប្រធានអង្គភាព**

**កន្លែងទទួល៖**

- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរ...រាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

  «ដើម្បីជូនជ្រាប»
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការិយាល័យ...
- ដូចប្រការ៣ «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ